ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ៣៦៦....សហវ.ប្រក

រាជធានីភ្នំពេញ. ថ្ងៃទី០៥... ខែ.ឧសភា ឆ្នាំ ២០១១

# ប្រកាស

## ស្តីពី

## ការបំពេញបន្ថែមគណនី នៃប្លង់គណនេយ្យទូទៅរបស់រដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តន៍ចំណាត់ថ្នាក់ថ្មី នៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម /១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ/បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតំឡើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យ

តាធ:រោភ:

- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៤៩១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅរបស់រដ្ឋ
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សម្រេច

**ប្រការ ១:** ត្រូវបានបំពេញបន្ថែមគណនី និងអនុគណនីនៅក្នុងប្លង់គណនេយ្យទូទៅរបស់រដ្ឋ ដែលមានឈ្មោះ និង លេខសម្គាល់ដូចខាងក្រោម :

- បង្កើតគណនីចំណាយថវិកា " បន្ទុកពន្ធគយលើការនាំចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៦៣៥ ស្ថិតក្នុងជំពូក " ពន្ធ និង អាករ " មានលេខសម្គាល់ ៦៣ ។
- បង្កើតគណនីចំណាយថវិកា " បន្ទុកពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៦៣៦ ស្ថិតក្នុងជំពូក " ពន្ធ និង អាករ " មានលេខសម្គាល់ ៦៣ ។
- បង្កើតអនុគណនីចំណូលថវិកា " អាករលើតម្លៃបន្ថែមរបបនាំចូលទំនិញ និងសម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៧០២៧ ស្ថិតក្នុងគណនី " ពន្ធទូទៅលើទ្រព្យសម្បត្តិ និងសេវា " មានលេខសម្គាល់ ៧០២ ។
- បង្កើតអនុគណនីចំណូលថវិកា " ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៧១០៧ ស្ថិតក្នុងគណនី " ពន្ធគយលើការនាំចូល " មានលេខសម្គាល់ ៧១០ ។

**ប្រការ ២: ប្រព្រឹត្តិកម្ម នៃគណនី និង អនុគណនី :**

គណនី និង អនុគណនី ដែលបានបំពេញបន្ថែមដូចប្រការ ១ មានប្រព្រឹត្តិកម្មដូចខាងក្រោម ៖

**- គណនី " ពន្ធគយលើការនាំចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) " មានលេខសម្គាល់ ៦៣៥ :**

គណនីលេខ ៦៣៥ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ពន្ធនាំចូល និងសម្ភារៈកសិកម្មដែលជាបន្ទុករបស់រដ្ឋ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នាំចូលទំនិញ និងសម្ភារៈកសិកម្ម ដែលជាបន្ទុករបស់រដ្ឋ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើនាំពន្ធចូលទំនិញ និង សម្ភារៈកសិកម្ម ( ជាបន្ទុករបស់រដ្ឋ ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាលើពន្ធនាំចូលទំនិញ និងសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**- គណនី " ពន្ធគយលើការនាំចូលទំនិញ ជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) " មានលេខសម្គាល់ ៦៣៦ :**

គណនីលេខ ៦៣៦ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថដែលជាបន្ទុករបស់រដ្ឋ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ)

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាលើពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាលើពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**- អនុគណនីចំណូលថវិកា " អាករលើតម្លៃបន្ថែមរបបនាំចូលទំនិញ និង សម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) " មានលេខសម្គាល់ ៧០២៧ :**

អនុគណនីលេខ ៧០២៧ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់អាករលើតម្លៃបន្ថែមលើការនាំចូលទំនិញ និងសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) ។ ការកត់ត្រាជាចំណូលថវិកាក្នុងគណនីលេខ ៧០២៧ ដើម្បីមានតុល្យភាពរវាងចំណាយថវិកា (បន្ទុករបស់រដ្ឋ) ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់អាករលើតម្លៃបន្ថែមលើការនាំចូលទំនិញនិង សម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់អាករលើតម្លៃបន្ថែមលើការនាំចូលទំនិញ និងសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ)

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកានូវអាករលើតម្លៃបន្ថែមលើការនាំចូលទំនិញ និងសម្ភារៈកសិកម្ម (ជាបន្ទុករបស់រដ្ឋ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**- អនុគណនីចំណូលថវិកា " ពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) " មានលេខសម្គាល់ ៧១០៧ :**

អនុគណនីលេខ ៧១០៧ បើកនៅអគ្គនាយកដ្ឋានរតនាគារជាតិ ប្រើសម្រាប់កត់ត្រាចំនួនទឹកប្រាក់

ចាត់ទុកជាចំណូលថវិកានូវទឹកប្រាក់ដែលបានកត់ត្រាជាចំណាយថវិកាជាបន្ទុករបស់រដ្ឋលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ ។ ការកត់ត្រាជាចំណូលថវិកាក្នុងគណនីលេខ ៧១០៧ ដើម្បីមានតុល្យភាពរវាងចំណាយថវិកាជាបន្ទុករបស់រដ្ឋ ។

**ការកត់ត្រា :**

ឥណពន្ធ : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់ពន្ធគយលើការនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) ដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាជាចំណូលថវិកានូវទឹកប្រាក់ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ)

សមតុល្យ : ឥណទេយ្យ បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកានូវទឹកប្រាក់ពន្ធនាំចូលទំនិជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ (ជាបន្ទុករបស់រដ្ឋ) ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

**ប្រការ ៣:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤:** ប្រកាសនេះចូលជាធរមានចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

***ចំលងជូន :***
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ